# ព្រះរាជក្រឹត្យ

នស/រកត/០៩០៤/២៨៤

## ស្តីពី

## ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**
**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍**
**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេច នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

## ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើត ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ឱ្យទទួលបន្ទុកសម្របសម្រួល ដឹកនាំ តាមដាន ត្រួតពិនិត្យមើលការអនុវត្ត និង លើកសំណើជូនរាជរដ្ឋាភិបាល លើរាល់កិច្ចការនៃកំណែទំរង់រដ្ឋ ការពង្រឹងអភិបាលកិច្ចល្អ និង កំណែទំរង់នានាតាមវិស័យសំខាន់ៗរបស់បណ្តាស្ថាប័នរដ្ឋ ស្របតាមកម្មវិធីនយោបាយ និង យុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាល ។

**មាត្រា ២.-**

ដើម្បីបំពេញបេសកកម្ម និង សម្រេចភារកិច្ចដូចមានចែងក្នុងមាត្រា ១ ខាងលើ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវបានជួយជាកម្លាំងដោយក្រុមប្រឹក្សាកំណែទំរង់មួយចំនួន ដែលទទួលខុសត្រូវផ្ទាល់ក្នុងការផ្តួចផ្តើមគំនិត និង អនុវត្តនូវកម្មវិធីកំណែទំរង់នានា ពាក់ព័ន្ធទៅនឹងក្រសួងស្ថាប័នរបស់ខ្លួន ស្ថាប័នរដ្ឋណាមួយ ឬ ក្នុងផ្នែកណាមួយនៃវិស័យរដ្ឋបាល សេដ្ឋកិច្ច និង សង្គមកិច្ចរបស់ព្រះរាជាណាចក្រកម្ពុជា ។

ក្រុមប្រឹក្សាកំណែទំរង់នីមួយៗ និង ស្ថាប័នរដ្ឋដែលបំពេញការងារកំណែទំរង់ ឬ អភិបាលកិច្ចល្អ ដែលមានក្នុងព្រះរាជក្រឹត្យនេះ ត្រូវបង្កើតឡើង ដោយអនុក្រឹត្យ ។

ក្រុមប្រឹក្សាកំណែទំរង់នីមួយៗ ត្រូវបានដឹកនាំដោយប្រធានមួយរូប និង មានអគ្គលេខាធិការដ្ឋានមួយធ្វើជាសេនាធិការទទួលបន្ទុកសម្របសម្រួល ដាក់ឱ្យដំណើរការ និង តាមដានជាអចិន្ត្រៃយ៍នូវការអនុវត្តការងារដែលស្ថិតនៅក្នុងយុត្តាធិការរបស់ប្រធាន ។

**មាត្រា ៣.-**

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ អាចអញ្ជើញសមាជិករាជរដ្ឋាភិបាល ឬ ឥស្សរជនដែលមានគុណសម្បត្តិគ្រប់គ្រាន់ មកចូលរួមក្នុងការប្រជុំរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៤.-**

ដើម្បីប្រតិបត្តិបេសកកម្ម ដូចមានចែងក្នុងមាត្រាខាងលើ ឱ្យបានសម្រេចជោគជ័យ ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវបំពេញមុខការ និង ភារកិច្ច ដូចតទៅ :

១- លើកសំណើស្តីពី ការបង្កើត ឬ ការផ្លាស់ប្តូរក្រុមប្រឹក្សា ឬ អង្គភាពនានា ដែលមានចរិតលក្ខណៈគតិយុត្តជាស្ថាប័នរដ្ឋ បំពេញការងារកំណែទំរង់តាមវិស័យនានា និង ពង្រឹងអភិបាលកិច្ច ។

២- តំរង់ទិស សម្របសម្រួល និង ត្រួតពិនិត្យសកម្មភាពការអនុវត្តន៍ការងារ និង វឌ្ឍនភាពនៃលទ្ធផលទាំងអស់របស់ក្រុមប្រឹក្សា និង អង្គភាពនីមួយៗ ។

៣- លើកសំណើជូនរាជរដ្ឋាភិបាល ក្នុងការតាក់តែងលិខិត និង បទដ្ឋានគតិយុត្ត និង បទប្បញ្ញត្តិចាំបាច់សំខាន់ៗ សំរាប់ដាក់ឱ្យដំណើរការកម្មវិធីកំណែទំរង់នានា និង ការពង្រឹងអភិបាលកិច្ចល្អ ។

៤- ចេញសេចក្តីសំរេច និង សេចក្តីណែនាំសំខាន់ៗ ដល់ការដាក់ឱ្យដំណើរការកម្មវិធីកំណែទំរង់នានា នៅក្នុងយុត្តាធិការរបស់ខ្លួន ។

**មាត្រា ៥.-**

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានសមាសភាពដូចតទៅ :

| | |
|---|---|
| ១- នាយករដ្ឋមន្ត្រី | ប្រធាន |
| ២- ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធានអចិន្ត្រៃយ៍ |
| ៤- ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងការពារជាតិ | សមាជិក |
| ៥- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៦- ឧបនាយករដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួង អភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧- ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | សមាជិក |

៨- ប្រធានក្រុមប្រឹក្សា និង ប្រធានអង្គភាពទាំងអស់ដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ជាសមាជិក ។

អង្គការលេខរបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវកំណត់នៅក្នុងឧបសម្ព័ន្ធ ដូចមានភ្ជាប់ជាមួយ ។

## ជំពូកទី ២

## អគ្គលេខាធិការដ្ឋាន

**មាត្រា ៦.-**

ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានអគ្គលេខាធិការដ្ឋានមួយ ជាអង្គភាពប្រតិបត្តិដែលត្រូវបានដឹកនាំ និងគ្រប់គ្រងដោយអគ្គលេខាធិការមួយរូប ។ អគ្គលេខាធិការដ្ឋាន ប្រើប្រាស់មន្ត្រីរាជការនៅក្នុងក្របខ័ណ្ឌមុខងារសាធារណៈ ។ អគ្គលេខាធិការនៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ មានអគ្គលេខាធិការរង និង ក្រុមទីប្រឹក្សាមួយចំនួន ជាជំនួយការ តាមការចាំបាច់ ។

អគ្គលេខាធិការ និង អគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសំណើររបស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៧.-**

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល គឺជាអគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

របៀបរបបការងារ និង ការបែងចែកភារកិច្ច របស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន នៃឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវកំណត់ដោយសេចក្តីសំរេចរបស់ប្រធានក្រុមប្រឹក្សាកំណែទំរង់រដ្ឋបាល តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ប្រធានឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

**មាត្រា ៨.-**

អគ្គលេខាធិការ មានភារកិច្ចរៀបចំរបៀបវារៈនៃការប្រជុំនានារបស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ផ្សព្វផ្សាយសេចក្តីសំរេច សម្របសម្រួល និង តាមដានការអនុវត្តន៍របស់ក្រុមប្រឹក្សា និង អង្គភាពនានា ហើយនិងធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារដែលសំរេចបាន ជូនឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៩.-**

ព្រះរាជក្រឹត្យលេខ នស / រកត / ០៣៩៩ /៧២ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៩ ស្តីពី ការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១០.-**

សម្តេចនាយករដ្ឋមន្ត្រី ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេច តាមស្មារតីនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១១.-**

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៤*

**ក្នុងព្រះបរមនាម និង តាមព្រះរាជត្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

នស/រកត.០៩០៤.២៨៦

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**ជា ស៊ីម**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

ព្រះមហាក្សត្រ សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានយកសេចក្តីជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

**ហត្ថលេខា**

**សុខ អាន**

លេខៈ ៧២៧ ចល

បានឃើញចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ កញ្ញា ឆ្នាំ២០០៤

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

[illegible] តាន់